# ពេលនេះជាពេលដែលត្រូវពង្រឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក និងប៉ាស៊ីហ្វិក

ជារៀងរាល់ពេលដែលខ្ញុំទទួលបានដំណឹងថាមានគ្រោះធម្មជាតិកើតឡើង គឺមានមនុស្សស្លាប់ រងរបួស ផ្ទះសំបែងត្រូវបំផ្លាញ បាត់បង់ការរស់នៅ ខ្ញុំដឹងថាយើងបានធ្វើសកម្មភាពដើម្បីកាត់បន្ថយផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនេះ ជាជាងការរង់ចាំរហូតដល់មានគ្រោះមហន្តរាយវាយលុកម្តងទៀត។

យើងមានឱកាសនេះតាមរយៈសន្និបាទពិភពលោកស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅទីក្រុង ស៊ែនដាយ ដែលស្វែងរកការតាក់តែងបញ្ចប់ផែនការជំនួសក្របខណ្ឌសកម្មភាពHyogo ដែលណែនាំអ្នកធ្វើគោលនយោបាយ និងអ្នកពាក់ព័ន្ធអន្តរជាតិនានាក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ សន្និបាទនេះជាឱកាសមួយ ដើម្បីរៀបចំគោលដៅថ្មីក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងប្រឆាំងនឹងភាពក្រីក្រ។

ផងប៉ះពាល់នៃគ្រោះធម្មជាតិមានទំហំធំណាស់រួចទៅហើយ គឺវាបានសម្លាប់ជីវិតមនុស្សជាង ២,៥លាននាក់ ខូចខាតដែលមានទំហំគិតជាទឹកប្រាក់ប្រមាណ ៤ ពាន់ពាន់លានដុល្លា ក្នុងរយៈពេល៣០ឆ្នាំកន្លងទៅនេះ ជាមួយនឹងការបំផ្លេចបំផ្លាញនៃកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍នានា។

ក្នុងតំបន់អាស៊ី ការកើនឡើងដ៏គំហុកនៃតំបន់ទីក្រុងជាមួយនឹងផែនការនៅមានកម្រិត វានឹងកំពុងតែបង្កើនការប្រឈមយ៉ាងលឿនរបស់ទីក្រុង ជាពិសេសទីក្រុងដែលមានដង់ស៊ីតេប្រជាជនច្រើន និងមានទីតាំងនៅតាមមាត់សមុទ្រ និងអាងទន្លេ។ ព្យុះ ហៃយ៉ាន ដែលមានសម្លាប់មនុស្សជាង ៧៣៥០នាក់នៅប្រទេសហ្វីលីពីនកាលពីឆ្នាំ២០១៣ បានបង្កើនអត្រាភាពក្រីក្រ១,២%។

បច្ចុប្បន្នយើងមានឧបករណ៍សម្រាប់កាត់បន្ថយផលប៉ះពាល់បែបនេះ។ ឧទាហរណ៍ ប្រព័ន្ធប្រកាសអាសន្នស្ទូណាមិនៅមហាសមុទ្រឥណ្ឌា ដែលបានដាក់បន្ទាប់ពីគ្រោះមហន្តរាយឆ្នាំ២០០៤ អាចបញ្ជូនសញ្ញាអាសន្នទៅមណ្ឌលប្រកាសអសន្នជាតិតែ១០នាទីនៃការរញ្ជួយដីមួយ ដែលវាអាចជួយកាត់បន្ថយការបាត់បង់អាយុជីវិតដល់ប្រជាជនទាំង២៨ប្រទេសបាន។

របាយការណ៍ដែលទើបតែចេញថ្មីៗរបស់ធនាគារពិភពលោក បានប្រើប្រាស់រូបភាពពីផ្កាយរណប និងផែនទីភូមិសាស្ត្រ ដើម្បីតាមដានការផ្លាស់ប្តូរទំរង់នៃការប្រើប្រាស់ដីក្នុងតំបន់អាស៊ី ដែលវាបានផ្តល់ជាទិន្នន័យអាចជួយឲ្យយើងធ្វើផែនការ និងធ្វើសេចក្តីសម្រេចចិត្តវិនិយោគ។

ជាទូទៅ ការងារដ៏ធំធេងនៃការសម្របទៅនឹងគ្រោះធម្មជាតិ គឺជាការចែករំលែកនៃការទទួលខុសត្រូវនៃរដ្ឋាភិបាល សហគមន៍ សហគមន៍អន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងអស់។

ការវាយតម្លៃហានិភ័យគ្រោះមហន្តរាយ និងគំនិតផ្តួចផ្តើមហិរញ្ញវត្ថុប៉ាស៊ីហ្វិក (PCRAFI) ដោយមានដៃគូដូចជា ប្រទេសជប៉ុន លេខាធិការដ្ឋានសហគមន៍ប៉ាស៊ីហ្វិក ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក មូលនិធិ សកលសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ និងការស្តារឡើងវិញ (GFDRR) និងសហភាពអ៊ឺរ៉ុប បានកសាងនូវ ការប្រមូលផ្តុំដ៏ធំមួយនៃព័ត៌មានភូមិសាស្ត្រសម្រាប់ហានិភ័យនៃគ្រោះធម្មជាតិនៅប្រទេសនានាក្នុងប្រជុំកោះនៃសមុទ្រប៉ាស៊ីហ្វិក។

ទិន្នន័យទាំងនេះ បានចូលរួមចំណែកក្នុងគម្រោងសាកល្បងនៃការធានារ៉ាប់រងហានិភ័យប៉ាស៊ីហ្វិក ដែលវាជាយន្តការអនុញ្ញាតឲ្យមានការចូលរួមពីថ្នាក់ប្រទេស ដើម្បីធ្វើឲ្យមានសុវត្ថិភាពដល់ការគ្រប់ដណ្តប់គ្រោះមហន្តរាយនៃការរញ្ជួយដី ស៊ូណាមិ និងព្យុះ ក្នុងទីផ្សាធានារ៉ាប់រងអន្តរជាតិ។ ក្នុងឆ្នាំ ២០១៣ ប្រទេសតុងហ្គា បានក្លាយជាប្រទេសទីមួយមុនគេដែលទទួលបានធានារ៉ាប់រងជាទឹកប្រាក់១,២៧លានដុល្លា ដែលផ្តល់ជូនជាបន្ទាន់បន្ទាប់ពីទទួលរងគ្រោះដោយព្យុះ Ian ។

ទន្ទឹមនឹងនេះដែរ ផែនការថ្នាក់ជាតិ និងកម្មវិធីពង្រីកនៅប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងវៀតណាម កំពុងតែផ្លាស់ប្តូរសហគមន៍រាប់រយដោយធ្វើឲ្យប្រសើរឡើងនៃការទទួលបានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងពង្រឹងការធុនទ្រាំរបស់ពួកគេក្នុងរយៈពេលវែងតាមរយៈប្រព័ន្ធប្រកាសអាសន្ន ផ្លូវសម្រាប់ជំលាសចេញ និងការបណ្តុះបណ្តាលគ្រាមានអាសន្ន។

ធនាគារពិភពលោកបានបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីជួយកសាងភាពធុនទ្រាំក្នុងគម្រោងទាំងអស់របស់ ខ្លួន។ គិតមកដល់ថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០១៤ ១០០%នៃគម្រោងដែលគាំទ្រដោយធនាគារពិភពលោកគឺបាន

ពិនិត្យលើហានិភ័យអាកាសធាតុនិងគ្រោះធម្មជាតិ ផ្អែកលើការពិនិត្យនេះ
យើងមានដាក់បញ្ចូលក្នុងការកាត់បន្ថយហានិភ័យទាំងនោះ។

សម្រាប់ទសវត្សរ៍ខាងមុខ ភាពធុនទ្រាំគួរត្រូវបានចាត់ទុកជាអាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងការទទួលខុសត្រូវ
ជាជាងការអភិវឌ្ឍបែបងដែលៗនៅតាមសហគមន៍។ វាមិនមានទីកន្លែងណាប្រសើរជាងនៅទីក្រុងសៀនដាយទេ
ដើម្បីទទួលស្គាល់ពេញលេញនូវការងារជាបន្ទាន់ ក៏ដូចជាផលប្រយោជន៍នៃវា   ការវិនិយោគលើភាពធុនទ្រាំនេះ។